# គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ

**រួមគិត រួមធ្វើ រួមទទួលខុសត្រូវ**

# សេចក្តីថ្លែងការណ៍

# ស្តីពីការប្រយុទ្ធប្រឆាំងអំពើពុករលួយ

អំពើពុករលួយ គឺជាជំងឺរាតត្បាតដ៏សាហាវមួយក្នុងសង្គម ហើយវាជាដើមហេតុនាំឲ្យកើតមានអំពើអយុត្តិធម៌ បង្កើតនូវគំលាតកាន់តែធំ រវាងអ្នកមានទ្រព្យសម្បត្តិដែលបានមកពីការកឹបកេង ជាមួយនឹងប្រជាពលរដ្ឋ នាំឲ្យបាត់បង់ស្មារតីសាមគ្គីភាព ហើយក៏អាចឈានទៅដល់ ការរង្គោះរង្គើ និងបាតុភាពអវិជ្ជមានផ្សេងទៀត ក្នុងសង្គមផងដែរ ។

មើលឃើញច្បាស់ នូវស្ថានភាពដ៏អាក្រក់របៀបនេះ **គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ** យល់ថា យើងត្រូវរួមគ្នាប្រយុទ្ធប្រឆាំង អំពើពុករលួយនេះជាបន្ទាន់ ។ ក៏ប៉ុន្តែ មានសំនួរត្រូវបានចោទឡើងថា តើយើងត្រូវលុបបំបាត់អំពើពុករលួយរបៀបណា ? ផ្តើមចេញពីទីណា ? ចម្លើយអាចនឹងមានច្រើន ។

ដោយឡែក គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ យល់ច្បាស់ថា ដើម្បីលុបបំបាត់អំពើពុករលួយ យើងត្រូវស្វែងយល់ និងរកឲ្យឃើញ ជាបឋមនូវប្រភពរបស់វាសិន ដើម្បីឈានទៅដល់ការគាស់រំលើង ។ ប្រភពមួយយ៉ាងជាក់ច្បាស់ និងជាចម្បងនៃអំពើពុករលួយ ដែលគ្រប់គ្នាមិនអាចបដិសេធបាន គឺការរំលោភអំណាច ដោយយកអំណាចទៅប្រើប្រាស់ដើម្បីកេងជាប្រយោជន៍សម្រាប់ បុគ្គល ក្រុមគ្រួសារ និងបក្ខពួក ។

ដោយផ្អែកលើការវិភាគប្រកបដោយហេតុផលយ៉ាងដូច្នេះ គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ បានប្តេជ្ញា ប្រកាន់ជំហរម៉ឺងម៉ាត់ និងមិនរាថយ ចូលរួមកំចាត់អំពើពុករលួយ តាមរយៈការដាក់ចេញនូវគោលនយោបាយស្នូលរបស់ខ្លួន សម្រាប់អនុវត្ត ដើម្បីធ្វើឲ្យមានតុល្យភាពអំណាច រវាងអ្នកកាន់អំណាច ឬអ្នកដឹកនាំប្រទេសជាមួយប្រជាពលរដ្ឋ ដែលជាម្ចាស់ប្រទេស ដោយប្រើយន្តការ៨ចំនុច ជាគន្លឹះ ៖

**១. ត្រូវកំណត់អាណត្តិនាយករដ្ឋមន្ត្រី ( ត្រឹមពីរអាណត្តិ ) :**

ការកំណត់ត្រឹមពីរអាណត្តិនេះ គឺជៀសវាងកុំឲ្យនាយករដ្ឋមន្ត្រី មានឱកាសបង្កើតជាបណ្តាញខ្សែរយៈ គ្រួសារ បក្ខពួក ក្នុងគ្រប់ស្ថាប័នរដ្ឋ ឬឯកជន ពង្រឹងអំណាចរហូតដល់បង្កើតជារបបផ្តាច់ការបក្ខពួក ក្រុមគ្រួសារនិយម បំផ្លាញ ដល់ផលប្រយោជន៍ជាតិ និង ប្រជាជន ។

**២. នាយករដ្ឋមន្ត្រីមិនត្រូវបានអនុញ្ញាតឲ្យបង្កើតក្រុមអង្គរក្សដោយខ្លួនឯង :**

ការបង្កើតក្រុមអង្គរក្សដោយខ្លួនឯង ស្មើនឹងការបង្កើតក្រុមប្រដាប់អាវុធមួយ អាចជាលទ្ធភាពយកទៅបំរើមហិច្ឆិតាអ្នកគ្រប់គ្រង ធ្វើការគៀបសង្កត់ ឬគំរាមកំហែងដល់ប្រជាពលរដ្ឋ ដើម្បីរក្សាការពារផលប្រយោជន៍បុគ្គល និងបន្តក្រាញ ក្នុងអំណាចរបស់ខ្លួន ។

**៣. នាយករដ្ឋមន្ត្រីត្រូវរស់នៅក្នុងនិវេសនដ្ឋានដែលផ្តល់ដោយរដ្ឋ :**

គឺជាវិធានការជួយដល់ការការពារសន្តិសុខ និងទំនុកបំរុងជីវភាពគ្រួសារនាយករដ្ឋមន្ត្រី ប្រកបដោយសុខុមាលភាព និងសេចក្តីថ្លៃថ្នូរ បង្កលក្ខណៈងាយស្រួលក្នុងការបំពេញការងារ ទទួលខុសត្រូវខ្ពស់ បំរើប្រទេសជាតិ ហើយក៏ជាការផ្តល់ មុខមាត់ដល់ប្រទេសជាតិផងដែរ ។

**៤. បង្កើតតុលាការរដ្ឋបាល :**

ដើម្បីបង្កលក្ខណៈងាយស្រួលដល់ពលរដ្ឋ ប្តឹងចំពោះទង្វើមិនសមស្រប ឬ រំលោភរបស់មន្ត្រីរាជការ ក្នុងការបំពេញការងារ ឬ អាចអោយពលរដ្ឋប្តឹងទៅស្ថាប័ននេះ ឲ្យពិនិត្យលើភាពមិនស្របច្បាប់ នៃលិខិតស្នាម ឬសេចក្តីសំរេចផ្សេងៗចេញដោយអង្គភាពរដ្ឋបាលសាធារណៈគ្រប់ជាន់ថ្នាក់ ។

**៥. ឋានន្តរសក្តិចាប់ពីឧត្តមសេនីយ៍យោធា និងនគរបាលត្រូវសុំសេចក្តីទុកចិត្តពីសភា :**

វិធានការនេះ គឺដើម្បីឲ្យសភាដែលជាតំណាងរបស់ពលរដ្ឋ អាចមានឥទ្ធិពលទៅលើនាយទាហាន និង នាយនគរបាលជាន់ខ្ពស់ ដែលជាអ្នកបញ្ជាលើកងកំលាំងប្រដាប់អាវុធរក្សា បូរណភាពទឹកដី និងសន្តិសុខ ស្ថេរភាពសង្គម ហើយក៏អាចជួយទប់ស្កាត់ ការប្រើប្រាស់កងកំលាំងប្រដាប់អាវុធ ជាឧបករណ៍ផ្តាច់ការ របស់មេគណបក្សកាន់អំណាចផងដែរ ។

**៦. អព្យាក្រឹតមន្ត្រីរាជការ :**

ការដាក់ឲ្យអនុវត្តចំណុចនេះ គឺដើម្បីធានាការចាត់តាំងបែងចែកការងារ ដល់មន្ត្រីរាជការចំជំនាញស្របតាមសមត្ថភាព និង ផ្តល់នូវសេចក្តីថ្លៃថ្នូរដល់មន្ត្រីរាជការដែលជាភ្នាក់ងាររបស់រដ្ឋ ។ ចៀសវាងការប្រើប្រាស់ មន្ត្រីរាជការជាឧបករណ៍ឃោសនា បំរើប្រយោជន៍គណបក្ស និងប្រព្រឹត្តអំពើពុករលួយ ។

**៧. ប្រជាពលរដ្ឋបោះឆ្នោតដោយផ្ទាល់ ជ្រើសរើស រឺទំលាក់តំណាង ឃុំ - សង្កាត់ / ក្រុង-ស្រុក-ខណ្ឌ/ ខេត្ត - រាជធានី :**

គឺជាវិធានការ ធ្វើឲ្យតំណាងពលរដ្ឋគ្រប់លំដាប់ថ្នាក់ ទទួលខុសត្រូវផ្ទាល់ ចំពោះមុខប្រជាពលរដ្ឋដែលជាម្ចាស់អំណាច ហើយក៏ជួយ កាត់ផ្តាច់ខ្សែរយៈបក្ខពួក ពីថ្នាក់ជាតិ ដល់មូលដ្ឋានដែលជាជំហានផ្តើមនៃការបង្កើតនូវអំណាចផ្តាច់ការ ។

**៨. ប្រើប្រព័ន្ធចម្រុះសំរាប់ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ:**

ប្រព័ន្ធបោះឆ្នោតចំមុខបានកាត់បន្ថយយ៉ាងខ្លាំងនូវឥទ្ធិពលរបស់មេបក្សទៅលើអ្នកតំណាងរាស្ត្រ។ ឥទ្ធិពលមេបក្ស អាចធ្វើឲ្យតំណាងរាស្ត្រ បាត់ឯករាជ្យភាព ខ្វល់ខ្វាយតែផលប្រយោជន៍បក្សខ្លួន ជាជាងគិតគូរដល់ ផលប្រយោជន៍ប្រជាពលរដ្ឋ ដែលជាម្ចាស់ប្រទេស ។ តំណាងរាស្ត្រមានឯករាជ្យ និងសេរីភាពគ្រប់គ្រាន់ ដោយគ្មានរងសម្ពាធ ពីជនមានឥទ្ធិពលណាម្នាក់នោះ តំណាងរាស្ត្រនោះ អាចបំពេញការងារ

ជួយកែតម្រង់រដ្ឋាភិបាលយ៉ាងមានប្រសិទ្ធិភាព និង រៀបចំធ្វើច្បាប់ណា ដែលបំរើដល់ផលប្រយោជន៍ជាតិ និងផលប្រយោជន៍ប្រជាជនពិតៗ ។

គោលនយោបាយនេះ អាចអនុវត្តទៅបានលុះត្រាតែមានការចូលរួមពីប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន ដោយការយល់ដឹងប្រាកដប្រជា និងការប្តេជ្ញាចិត្តប្រកបទៅដោយការទទួលខុសត្រូវខ្ពស់ ក្នុងការបង្កើតសង្គមមួយ ដែលមិនអនុញ្ញាតឲ្យបុគ្គលណាម្នាក់ ឬក្រុមណាមួយមានអំណាចពោរពាស រហូតដល់ច្បាប់គ្រប់គ្រងមិនបាន ឬឲ្យបុគ្គលនោះស្ថិតនៅពីលើច្បាប់រដ្ឋ ។ យើងអាចនិយាយម្យ៉ាងទៀតបានថា យើងរួមគ្នាក្នុងគោលដៅបង្កើត *« មាតុភូមិមួយ ដែលពួកយើងរស់នៅដោយស្មើភាពគ្នាក្នុងភាពជាម្ចាស់ »* ។

ភ្នំពេញ ថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០១៣

អាស័យដ្ឋានផ្ទះលេខ ១០៨ B២ ផ្លូវ ៣១៥ សង្កាត់ បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ៖ 012 232 753 / 012 646 681
www.camldp.org / Facebook: Ldp Share / Paltalk: Room Koun Khmer